# ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សអំពាវនាវសុំឱ្យបញ្ចប់និទណ្ឌភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន

*ខាងក្រោមនេះ គឺជាសារលិខិតរបស់លោកស្រី ល្វីស អាបួរ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅក្នុងឱកាសទិវាសេរីភាពសារព័ត៌មានពិភពលោក នៅថ្ងៃទី ៣ ខែ ឧសភា :*

ទិវាសេរីភាពសារព័ត៌មានពិភពលោក គឺជាឱកាសរំលឹកសិទ្ធិមួយ ក្នុងចំណោមសិទ្ធិមូលដ្ឋានគ្រឹះដទៃទៀតនៃសិទ្ធិមនុស្ស ដែលមានចែងត្រង់មាត្រា១៩ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងដើម្បីចងក្រងទុកអំពីស្ថានភាពនៃការទទួលបាននូវសិទ្ធិជាមូលដ្ឋាននេះនៅជុំវិញពិភពលោក ។

កាលពីពេលមុន មិនមានប្រទេសច្រើនទេបានអះអាងថានឹងគោរព និង ការពារដល់សិទ្ធិខាងសារព័ត៌មានក្នុងការបំពេញការងារដោយសេរីដោយមិនមានការរំខាន ឬការគាបសង្កត់ឡើយ ។ ម្យ៉ាងវិញទៀត ប្រទេសទាំងនោះ មិនបានផ្ដល់លទ្ធភាពដល់យើងទាំងអស់គ្នាដើម្បីចូលរួមចំណែកក្នុងការកសាងសង្គមសេរី ពីព្រោះប្រជាពលរដ្ឋដែលទទួលព័ត៌មាន ស្ថិតនៅក្រោមការគំរាមកំហែងយ៉ាងខ្លាំង ។ ក្នុងឆ្នាំ២០០៦ មានអ្នកសារព័ត៌មាន និង បុគ្គលិកសារព័ត៌មានច្រើនជាង១៥០ នាក់ ត្រូវបានសំលាប់ ដែលចំនួននេះច្រើនជាងពេលណាៗទាំងអស់ ចាប់តាំងពីភាពតានតឹងនេះកើតមាន ។

ប្រទេសដែលមានជំលោះ គឺជាកន្លែងគ្រោះថ្នាក់បំផុតសំរាប់អ្នកសារព័ត៌មាន ហើយនៅក្នុងឆ្នាំកន្លងទៅមិនមានការលើកលែងទេ ។ បុគ្គលិកសារព័ត៌មាន ជារឿយៗបានក្លាយជាជនរងគ្រោះដោយសារការប្រឈមមុខគ្នាដោយអាវុធ ហើយជារឿយៗពួកគេបានក្លាយជាចំណុចគោលដៅដោយចេតនា ដោយភាគីសង្គ្រាមនានា ដែលមានផលប្រយោជន៍ក្នុងប្រតិបត្តិការអាណាមិក ។ ប៉ុន្តែអ្នកសារព័ត៌មានក៏ត្រូវបានគេសំលាប់ យ៉ាយី និងបំភិតបំភ័យ -- ដោយអាជ្ញាធរ ក្រុមជនប្រដាប់អាវុធ ឬឧក្រិដ្ឋកម្មប្រដាប់អាវុធ -- នៅក្នុងប្រទេសជាច្រើនដែលមានសុខសន្តិភាពជាធម្មតា ។ ទោះជាមាន ឬគ្មានសង្គ្រាមក្តី ប្រទេស ដែលគ្រោះថ្នាក់បំផុតសំរាប់ការងារសារព័ត៌មាន បង្ហាញពីលក្ខណៈទូទៅមួយគឺថា: ប្រទេសទាំងនោះ ស្ទើរតែមិនអាចនាំខ្លួនជនដែលសំលាប់ និងវាយប្រហារលើអ្នកសារព័ត៌មានទៅផ្តន្ទាទោសតាម

ច្បាប់បានឡើយ ។ ការរីករាលដាលនៃនិទណ្ឌភាព ពិតជាដើរតួនាទីដ៏ចម្បងដល់ការធ្វើឱ្យកើនចំនួន នៃការវាយប្រហារលើអ្នកសារព័ត៌មាន និង ការរំលោភបំពានលើសេរីភាពក្នុងការសំដែងមតិ ។

នៅចំពោះមុខគ្រោះថ្នាក់ទាំងនេះ សាធារណៈជនជាច្រើនលើពិភពលោក មិនបានទទួលព័ត៌មានច្រើនទេ ។ ការនេះបង្ហាញពីការចូលរួមចំណែកទាំងញាប់ញ័រចំពោះការតស៊ូស្វិតស្វាញ និងសេចក្តីក្លាហានរបស់អ្នកសារព័ត៌មាន និងបុគ្គលិកសារព័ត៌មាន ទាំងសារព័ត៌មាន "ចាស់ " ទាំងសារព័ត៌មាន " ថ្មី " និងជាភស្តុតាងបង្ហាញពីការស្រេកឃ្លានព័ត៌មាន និងការចង់ដឹងចង់ឮ ដែលមិនអាចអត់បាន ។ ប៉ុន្តែ ទោះជាពួកគេទទួលស្គាល់ថាការព្យាយាមកាត់បន្ថយការសំដែងមតិដោយសេរី គឺជាចុងក្រោយ ឥតប្រយោជន៍ក៏ដោយ ក៏រដ្ឋាភិបាលនិងអាជ្ញាធរមានកាតព្វកិច្ចត្រូវតែគោរពសិទ្ធិមនុស្សគ្រប់រូប ក្នុងការសំដែងមតិ ដោយគ្មានការរំខាន និងដើម្បីស្វែងរកទទួល និងចែករំលែកព័ត៌មាន តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងៗ និងដោយគ្មានព្រំដែន ។ ដូច្នេះ ឆ្លៀតឱកាសនេះ ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាល និងអាជ្ញាធរនានាឱ្យគោរព ឬធ្វើការប្តេជ្ញាចិត្តជាថ្មី ដើម្បីធានាការពារដក់ការអនុវត្តន៍សេរីភាពក្នុងការសំដែងមតិ ធានាសុវត្ថិភាពដល់អ្នកសារព័ត៌មាន និងបញ្ចប់និទណ្ឌភាពសំរាប់ឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន ។

José Luis Díaz
Information Officer, Spokesperson
Office of the High Commissioner for Human Rights
tel. +4122 917 9242
jdiaz@ohchr.org
For press inquiries and interview requests:
press-info@ohchr.org